# កិច្ចការបញ្ចប់មេរៀនទី៤១-ឥទ្ធិពលនៃគ្រឿងស្រវឹង

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

| | | |
|---|---|---|
| ឯអ្នកប្រមឹក | ប្រមូលកនធឹក | ធ្វើភឿននឹងក្មេង |
| សម្ដីច្រើនតឹង | ស្រវឹងវង្វេង | ជំហរអួតក្អេង |
| | មិនចេះក្រខ្សត់ ។ | |
| អួតទាំងបំពាន | ផឹកម៉ែ្វលុយមាន | ផឹកម៉ែ្វលុយអត់ |
| ឯងចេះតែកិន | ចិនចេះតែកត់ | ផឹកដល់កំណត់ |
| | យកស្រែបញ្ចាំ ។ | |
| សល់ថ្នាលមួយពីរ | វាតគោស្មោរស៊ី | មិនគិតខ្លាចកម្ម |
| ផឹកជ្រុលហួសបទ | អត់បាយរាល់ឆ្នាំ | អស់ស្រែបញ្ចាំ |
| | បញ្ចាំកូនទៀត ។ | |

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើអត្ថបទនេះនិយាយអំពីអ្វី ?

☐ក. ជីវភាពក្រីក្ររបស់អ្នកស្រុក ☐ខ. របររកស៊ី លក់ដូរ

☐គ. ឥទ្ធិពលនៃគ្រឿងស្រវឹង ☐ឃ. មិត្តភក្តិគូកន

២. តើអត្ថន័យមួយណាត្រូវនឹងមេសូត្រខាងលើ ?

☐ក. អ្នកប្រមឹកមានប្រយោជន៍ដល់គ្រួសារ ☐ខ. អ្នកប្រមឹកតែងជួយដល់ជនក្រីក្រ

☐គ. អ្នកប្រមឹកធ្វើឱ្យគ្រួសារជួបការលំបាក ☐ឃ. អ្នកប្រមឹកធ្វើឱ្យគ្រួសារមានសុភមង្គល

៣. តើស្រាមានសារធាតុអ្វី ?

☐ក. សារធាតុបំប៉នកម្លាំង ☐ខ. សារធាតុជួយដល់សុខភាពល្អ

☐គ. ការថ្នាំព្យាបាលជំងឺ ☐ឃ. សារធាតុញៀន

៤. តើអ្នកផឹកស្រាច្រើនប្រើសម្ដីដូចម្ដេច ?

☐ក. សម្ដីសុភាពទន់ភ្លន់ ☐ខ. សម្ដីថ្លៃថ្នូរគួរឱ្យគោរព

☐គ. សម្ដីតឹង អួតក្អេងក្អាង វង្វេងភាន់ភាំង ☐ឃ. សម្ដី រួសរាយគួរឱ្យស្រឡាញ់

LIVEWORKSHEETS

៥. តើអ្នកផឹកស្រាដល់កំណត់ បើអត់លុយផឹក គាត់ធ្វើបែបណា ?

☐ក. យកស្រែ និងកូនទៅបញ្ចាំ ☐ខ. ឈប់ផឹក

☐គ. រកការងារធ្វើ ☐ឃ. ដេកនៅផ្ទះ

៦. តើអត្ថបទមេសូត្រខាងលើ ចង់អប់រំអ្វីដល់អ្នក ?

☐ក. យកគំរូតាម ☐ខ. ខិតខំរៀនសូត្រ

☐គ. ចៀសឆ្ងាយពីគ្រឿងស្រវឹង ☐ឃ. ស្ដាប់តាមដំបូន្មានឪពុកម្ដាយ

៧. ចូររកបដិសព្ទនឹងពាក្យ " ខ្លាច " ។

☐ក. ភ័យ ☐ខ. ហ៊ាន

☐គ. មិនខ្លាច ☐ឃ. ខ្វះខាត

៨. ចូររកវេវចនសព្ទនឹងពាក្យ " ក្លើ " ។

☐ក. បងប្អូន ☐ខ. ខ្លាំង

☐គ. ភឿន ☐ឃ. សត្រូវ

៩. ចូររកពាក្យចួននៅក្នុងអត្ថបទខាងលើក្នុងវគ្គទី៣

- តើពាក្យ " ពីរ " ចួននឹងពាក្យអ្វី ?

  ☐ក. កម្ម ☐ខ. វាយ

  ☐គ. ខ្លាច ☐ឃ. ស៊ី

- តើពាក្យ " កម្ម " ចួននឹងពាក្យអ្វី ?

  ☐ក. បទ និង អត់ ☐ខ. ខ្លាំង

  ☐គ. ឆ្នាំ និង បញ្ចាំ ☐ឃ. សត្រូវ

➢ សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោម

➢ កម្ម ( ) ..................................................................................................

➢ សុរា ( ) ..................................................................................................

➢ ប្រមឹក ( )..................................................................................................

LIVEWORKSHEETS

២. ចូររៀបពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ឱ្យបានជាឃ្លាត្រឹមត្រូវ ។

ក.

| | | | | | |
|---|---|---|---|---|---|
| ធ្វើឱ្យ | វង្វេង | សុរា | ស្មារតី | អ្នកសេព | តែង |

..........................................................................................................

ខ.

| | | | | | |
|---|---|---|---|---|---|
| ហិង្សា | គ្រឿងស្រវឹង | សេព | ក្នុងគ្រួសារ | អំពើ | នាំឱ្យ |

..........................................................................................................

៣. ចូរជ្រើសរើសពាក្យខាងក្រោមទៅបំពេញវគ្គមេសូត្រខាងក្រោមឱ្យបានត្រឹមត្រូវ ។

ប្រមឹក   កំណត់   ក្មេង   ស្មារតី   ក្រខ្សត់   បំពាន   រាល់ឆ្នាំ   ថ្នាល   ស្រវឹង   ខ្លាច

ឯអ្នកប្រមឹក....  ប្រមូលកនផឹក  ធ្វើភឿននឹង............

សម្ដីច្រើនតឹង  ............វង្វេង  ជំហាររអួតក្អេង

មិនចេះ............. ។

អួតទាំង............  ផឹកម៉្ញៃលុយមាន  ផឹកម៉្ញៃលុយអត់

ឯងចេះតែកិន  ចិនចេះតែកត់  ផឹកដល់.............

យកស្រែបញ្ចាំ ។

សល់...........មួយពីរ  វាតគោស្ទៀរស៊ី  មិនគិត.........កម្ម

ផឹកជ្រុលហួសបទ  អត់បាយ............  អស់ស្រែបញ្ចាំ

បញ្ចាំកូនទៀត ។

LIVEWORKSHEETS